# លក្ខនិកៈរបស់អង្គការ សុខភាព សិក្សាធិការ និងការផ្សព្វផ្សាយដល់សង្គមមនុស្ស របស់ខេត្តសៀមរាប (ស.ស.ក.ស)

## បុព្វកថា

សុខភាពសិក្សាធិការ និងការផ្សព្វផ្សាយដល់ សង្គមមនុស្ស របស់ខេត្តសៀមរាប គឺជាអង្គការក្រៅរដ្ឋាភិបាល ក្នុងស្រុកមួយ ដែលរួមគ្នាជាមួយប្រជាពលរដ្ឋ អ្នកប្រកបរបរជួញដូរ និងអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ និងសហគមន៍ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ក្នុងស្រុក និងពង្រឹងបន្ថែមរវាង អន្តរផ្នែកសុខភាពសិក្សាធិការ និងការកើតមានរឿងរ៉ាវសង្គម នៅក្នុងសហគមន៍ ដូចជា វិសមភាពយេនឌ័រ, សុខមាលភាពនិងសុវត្ថិភាព កន្លែងធ្វើការ, ការការពារ ការចំលងមេរោគអេដស៍/ជំងឺអេដស៍ ចំពោះបុរស, ស្ត្រី និងយុវវ័យដែលស្ថិតនៅ ក្នុងសភាពប្រឈមមុខនិងគ្រោះថ្នាក់នៃការឆ្លង។ ស.ស.ក.ស មានបំណងចង់កាត់បន្ថយហានិភ័យ សង្គម និងសុខភាពរបស់សហគមន៍ ក្នុងខណៈពេលដែលកំពុងធ្វើការងារដើម្បីជំរុញ ដល់ស្ត្រី និងអ្នកដទៃទៀត ដែល មិនរួមបញ្ចូលពីការពង្រឹង ផ្នែកសេដ្ឋកិច្ច ឱណាមិកបច្ចុប្បន្ន របស់សហគមន៍ក្នុងស្រុក។

## ប្រការ១: នាមករណ៍

នាមករណ៏របស់អង្គការគឺ សុខភាព សិក្សាធិការ និង ការផ្សព្វផ្សាយដល់សង្គមមនុស្ស របស់ខេត្តសៀមរាប សរសេរកាត់ ស.ស.ក.ស។

## ប្រការ២: អស័យដ្ឋាន

**ស.ស.ក.ស** មានទីតាំងបណ្តោះអាសន្ន ស្ថិតនៅផ្ទះលេខ ៤៨៣ ក្រុមទី១ ភូមិស្ទឹងថ្មី, ឃុំស្វាយដង្គុំ, ស្រុកសៀមរាប,ខេត្តសៀមរាបដែលរង់ចាំការិយាល័យអចិន្ត្រៃយ៏របស់ខ្លួន។ គណនីធនាគារមាននៅ

ធានាគារពាណិជ្ជកម្មកម្ពុជា សាខាខេត្តសៀមរាប លេខ១៣០ ផ្លូវស៊ីវុត្ថា ទីរួមខេត្តសៀមរាប ទូរស័ព្ទលេខ ០៦៣ ៩៦៤ ៣៩២ ។

## ប្រការ៣: ស្ថានភាព

ស.ស.ក.សជាអង្គការដែលមិនប្រកាន់សាសនា,មិនមាននិន្នាការនយោបាយមិនគិតពី ផលប្រយោជន៏ និងជាអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ហិរញ្ញប្បទានដោយឯករាជ្យ ដល់ការងារ របស់ខ្លួន តាមរយះការបិរច្ចាក និងអំណោយពីម្ចាស់ជំនួយដែលគាំទ្រ មូលនិធិ និងសាជីវកម្ម អន្តរជាតិ។

## ប្រការ៤: ប្រវត្តិ

នៅដើមខែកុម្ភៈ ឆ្នាំ២០០០ ក្រុមគ្រូពេទ្យ និងបុគ្គលិកពេទ្យ, បុគ្គលិកសណ្ឋាគារ ទេសចរណ៏ និង អ្នកប្រកបរបរជួញដូរមួយក្រុម នៅក្នុងខេត្តសៀមរាប ព្រមទាំងប្រជាពលរដ្ឋ បានធ្វើការជាមួយ អ្នកស្រាវជ្រាវផ្នែកសង្គម និងសុខភាពអន្តរជាតិ ដើម្បីបង្កើតវិធីជាក់លាក់ និងមានប្រសិទ្ធភាពមួយ ក្នុងការចូលរួមការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៏ជំងឺអេដស៏ នៅក្នុង ខេត្តសៀមរាប។ នៅឆ្នាំ ២០០១-២០០៣ ក្រុមនេះដែលទទួលបាននូវមូលនិធិ ពី មូលនិធិ AIDS Elton John បានចាប់ផ្តើមបណ្តុះបណ្តាលស្ត្រីក្នុងស្រុកដើម្បីអប់រំដល់ស្ត្រីដូចគ្នាអំពីការ ផ្លាស់ប្តូរឥរិយាបទ ក្នុងការ ប្រព្រឹត្តផ្លូវភេទដើម្បីការពារការឆ្លងមេរោគអេដស៏ជំងឺអេដស៏ និងជំងឺ ឆ្លងតាមផ្លូវភេទផ្សេងទៀត។ ការប្រឈមមុខ ទៅនិងវិបត្តិនៃការឆ្លងរាលដាលនៃមេរោគអេដស៏ ជំងឺអេដស៏ (២០០៣-២០០៥) នៅក្នុងខេត្តសៀមរាប, ការស្វែងរក កន្លែងធ្វើការដែលមាន សុខមាលភាព និងសុវត្ថិភាពសំរាប់ស្ត្រី បច្ចុប្បន្ននេះនៅតែជាបញ្ហានៅក្នុងខេត្ត ។ អង្គការមិនមែន រដ្ឋាភិបាលអាចនិងសំរេចចិត្ត ដើម្បីផ្តើមពិនិត្យដោះស្រាយបញ្ហា ដទៃទៀតដែលទាក់ទងទៅនិង សុខភាព, សិក្សាធិការ និង រឿងរ៉ាវសង្គមផ្សេងៗ ។

## ប្រការ៥: និមិត្តសញ្ញាអង្គការ

ផ្លាកសញ្ញាអង្គការ ស.ស.ក.ស មានរូបភាពសមាជិកមួយចំនួន និង ទីប្រឹក្សានៅខាងមុខប្រាសាទ អង្គរវត្ត, មាននិមិត្តសញ្ញាបីដែលតំណាងឱ្យ សុខភាព/វេជ្ជសាស្ត្រ សិក្សាធិការ និងជំអឺអេដស៏

ដែលជាបញ្ហាសង្គម អមទៅដោយឈ្មោះអង្គការ ជាភាសាខ្មែរ, បារាំង និងអង់គ្លេស ។

## ប្រការ៦: គោលបំណង, បេសកកម្ម, ទស្សនៈ និង គោលដៅ

**ស.ស.ក.ស.** រួមគ្នាជាមួយប្រជាពលរដ្ឋ, អ្នកប្រកបរបរជំនួញ, អ្នកជំនាញវេជ្ជសាស្ត្រ និងសហគមន៍ ដើម្បីជួយពួកគេក្នុងការទំនាក់ទំនង នៅពេលចាំបាច់ដល់អ្នកជំនាញទាំងនោះ ជាមួយនិងធនធានពីខាងក្រៅ។ ទស្សនះវិស័យគ្រប់ផ្នែក ត្រូវបានរៀបចំដើម្បីបង្កើនការធ្វើការងារជួយគ្នាទៅវិញទៅមក ក្នុងចំណោមប្រជាពលរដ្ឋ អ្នកផ្តល់សេវាកម្ម ភ្នាក់ងាររដ្ឋាភិបាល, ឧស្សាហកម្មក្នុងស្រុក និងអន្តរជាតិ ។

**ស.ស.ក.ស.**ប្រឹងប្រែងពង្រឹងហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុក និង ការកសាងបន្ថែមនូវសមត្ថភាពក្នុងការធ្វើការទំនាក់ទំនងជាអន្តរផ្នែកនៃសុខភាព, សិក្សាធិការ និងបញ្ហាសង្គមផ្សេងៗ ក្នុងសហគមន៍។ បញ្ហារបស់ ស.ស.ក.ស គឺវិសមភាពយេនឌ័រ, សុខមាលភាព និងសុវត្ថិភាពកន្លែងធ្វើការដែលទាក់ទងទៅនិងការការពារការឆ្លងមេរោគអេដស៏ ជំងឺអេដស៍ ចំពោះបុរស ស្ត្រី ព្រមទាំងយុវវ័យ ដែលកំពុងតែប្រឈមមុខ និងការឆ្លង ។

**ស.ស.ក.ស.** រកឃើញ និងអនុវត្តន៏ នូវយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពសំខាន់ ក្នុងការកាត់បន្ថយហានិភ័យសង្គម និងសុខមាលភាពរបស់សហគមន៏។

**ស.ស.ក.ស.** ខិតខំធ្វើយ៉ាងណាដើម្បី អភិវឌ្ឍន៏ការអប់រំ និង ឱកាសក្នុងការប្រកបការងារក្នុងស្រុករបស់ស្ត្រី និងអ្នកដទៃដែលមិនរាប់បញ្ចូលពីការពង្រីកសេដ្ឋកិច្ច ឪណាមិចបច្ចុប្បន្ន របស់សហកមន៏នៅក្នុងស្រុក ។

**ស.ស.ក.ស.** បង្កើតនូវវិធីសាស្ត្រ និងសំភារៈដ៏ជាក់លាក់ និងមានប្រសិទ្ធភាពជាភាសាខ្មែរ ដើម្បីចូលរួមក្នុងការ កាត់បន្ថយការរីករាលដាលមេរោគអេដស៍ នៅក្នុងខេត្តសៀមរាប ។ បច្ចេកទេស ការពារ និងវិធីសាស្ត្របណ្តុះបណ្តាល ទាំងឡាយគឺត្រូវបានរួមចំណែកជាមួយនិង

ភ្នាក់ងាររដ្ឋាភិបាល ផ្សេងៗ អង្គការក្រៅរដ្ឋាភិបាល ក្នុងស្រុក និងអន្តរជាតិ ដែលអាចធ្វើការប្រើប្រាស់សំភារៈផ្សព្វផ្សាយរបស់អង្គការ ស.ស.ក.ស. ដោយសេរី ។

**ស.ស.ក.ស.** និងបណ្តុះបណ្តាលស្ត្រី និងបុរសទាំងឡាយ ក្នុងស្រុក ដើម្បីធ្វើការអប់រំបន្តដល់មិត្រភ័ក្ត្ររួមអាជីពរបស់ពួកគេ អំពីការផ្លាស់ប្តូរការប្រព្រឹត្ត ដែលជាមូលហេតុនៃការឆ្លងរាលដាលនៃមេរោគអេសដ៏/ជំងឺអេដស៍ និងជំងឺកាមរោគដទៃទៀត ។

**ស.ស.ក.ស.** ស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុ ពីមូលនិធិក្រៅប្រទេសផ្សេងៗ ហើយបន្ទាប់មកស្វែងរកកិច្ចសហប្រតិបត្តិការ និងចូលរួម ជាមួយនិងជំនួញសហគមន៍ក្នុងស្រុក ដើម្បីធានានូវនិរន្តភាពរយះពេលវែង នាពេលអនាគត ។

តាមរយះភាពជាដៃគូ និងអនុស្សារណៈនៃការយោគយល់ ស.ស.ក.ស បង្កើតកម្មវិធីសហការណ៏ជាមួយបណ្តាញការងារនៅក្នុងខេត្ត និង ជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ព្រមទាំងជាមួយមន្ទីរ-ក្រសួងពាក់ព័ន្ធដូចជា ក្រសួងសុខាភិបាល, មន្ទីរសុខាភិបាលខេត្ត ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី និង អតីតយុទ្ធជនខេត្ត, ក្រសួងទេសចរណ៏ និងមន្ទីរទេសចរណ៏ខេត្ត, លេខាធិការដ្ឋានអេដស៏ខេត្ត និង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៏សើរស្បែក និងកាមរោគ ..។

## ប្រការ៧: សមាជិកភាពនៅក្នុងអង្គការ ស.ស.ក.ស

សមាជិកភាពនៃ ស.ស.ក.ស ចែកចេញជាបីប្រភេទ:

**១)** សមាជិកកិត្តិយស ជាសមាជិកនៅក្នុងខេត្ត និងមកពីកន្លែងដទៃទៀត ដែលបានជួយជ្រោមជ្រែងក្នុងការបង្កើតឱ្យមានអង្គការក្រៅរដ្ឋាភិបាល ស.ស.ក.ស ចាប់តាំងពីឆ្នាំ ២០០០ ។ ពួកគេអាចបោះឆ្នោតនៅក្នុងកិច្ចប្រជុំ ។

**២)** សមាជិកសកម្មជាមនុស្សដែលមានអាយុពី ១៨ ឆ្នាំឡើងទៅដែលចូលរួមក្នុង កិច្ចប្រជុំប្រចាំឆ្នាំ ហើយចុះហត្ថលេខាលើបញ្ជីរឬអ្នកដែលបញ្ជាក់អំពីសមាជិកប្រតិបត្តិដែលពួកគេចង់ ចូលរួម ។ ពួកគេអាចបោះឆ្នោតបាននៅក្នុងគ្រប់អង្គប្រជុំ។

៣) សហសមាជិក ដែលជាអ្នកមិនស្ថិតនៅក្នុងប្រភេទទី ១ និង ទី២ ទេ ប៉ុន្តែជាអ្នកដែលបានជ្រាបអំពីសកម្មភាពការងាររបស់អង្គការក្រៅរដ្ឋាភិបាល ហើយចូលរួមគោលបំណងរបស់ខ្លួន ឧ. ដូចជា យុវវ័យ ឬ អ្នកដែលរស់នៅឆ្ងាយពីខេត្តសៀមរាប ។ ពួកគេមិនបានចូលរួមក្នុងការប្រជុំបោះឆ្នោតប្រចាំឆ្នាំទេ។

៤) សមាជិកគាំទ្រ ជាសហសមាជិកដែលគាំទ្រ ការងាររបស់អង្គការក្រៅរដ្ឋាភិបាល ផ្នែកហិរញ្ញវត្ថុដោយស្ម័គ្រចិត្ត ។

## ប្រការ៨: ការទទួលខុសត្រូវ និងអត់យឯកសិទ្ធ របស់សមាជិកភាព

សមាជិកគ្រប់រូបយល់ព្រមគោរពគោលដៅ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គការ ក្រៅរដ្ឋាភិបាល ។ ការខកខានមិនបាន គោរពតាមបទបញ្ជារបស់អង្គការ អាចនាំមកនូវការដកហូតពីសមាជិកភាពរបស់គណៈកម្មាធិការប្រតិបត្តិដោយសំលេងភាគច្រើន ។

## ប្រការ៩: កិច្ចប្រជុំទូទៅប្រចាំឆ្នាំ

អង្គការ និងបង្កើតកិច្ចប្រជុំទូទៅប្រចាំឆ្នាំម្តងក្នុងមួយឆ្នាំ តាមថ្ងៃបរិច្ឆេទដែលបង្កើតឡើងដោយគណៈកម្មាការប្រតិបត្តិ ។ សមាជិកគ្រប់រូបនិងត្រូវបានជូនដំណឹងរយះពេលបីសប្តាហ៍ជាមុន ។ អង្គការនិងប្រើប្រាស់ការប្រជុំប្រចាំឆ្នាំរបស់ខ្លួនដើម្បីទទួលយកនូវរបាយការណ៍អំពីសកម្មភាពការងារប្រចាំឆ្នាំ កន្លងទៅ របាយការណ៍ហិរញ្ញវត្ថុ ការបោះឆ្នោតជ្រើសរើសសមាជិកជូនគណៈ-កម្មាធិការប្រតិបត្តិ ហើយដំណើរការការងារថ្មីៗ ដែលត្រូវការ ។

នាយកប្រតិបត្តិអាចសំរេច ដូចឆ្នាំកន្លងទៅ ដើម្បីភ្ជាប់កិច្ចប្រជុំទូទៅប្រចាំឆ្នាំនៅក្នុងសន្និសិទ្ធតូចៗ ឬក៏នៅក្នុងពេលញ៉ាំអាហារពេលល្ងាច ដើម្បីរាយការណ៍អំពីសកម្មភាពការអប់រំនៅក្នុងសហគមន៍របស់ខ្លួនផ្ទាល់ ដែលក្នុងនោះអង្គការ ឬស្ថាប័នដទៃទៀត ដែលមានគោលបំណងប្រហាក់ប្រហែលគ្នា និងត្រូវបានអញ្ជើញចូលរួម ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ។

## ប្រការ១០: អធិការកិច្ច

អង្គការនិងមានបីក្រុមក្នុងការជួយឱ្យមានដំណើរការការងារ និងបំពេញគោលបំណងរបស់ខ្លួនគឺៈ

គណៈកម្មការផ្តល់ការប្រឹក្សា, គណៈកម្មការប្រតិបត្តិ និងរដ្ឋបាលគំរោង ។

## ប្រការ១១: គណៈកម្មការផ្តល់ការប្រឹក្សា

គណៈកម្មការផ្តល់ការប្រឹក្សា រួមមានអ្នកដែលមានកិត្តិយស និងត្រូវទទួលស្គាល់ដោយសហគមន៍ និងអ្នកមកពីកន្លែងដទៃទៀត ដែលអាចផ្តល់ដល់អង្គការនូវការផ្លាស់ប្តូរគោលបំណង និងសេចក្តីប្រាថ្នា របស់អង្គការ ហើយជាអ្នកដែលសុខចិត្តយល់ព្រមណែនាំដល់ការប្រតិបត្តិ និងរដ្ឋបាលក្នុងផ្នែកជំនាញរបស់ពួកគេ ។ សមាជិកកិត្តិយសជាច្រើនរបស់អង្គការ ជាពិសេសគណៈកម្មការផ្តល់ការប្រឹក្សាត្រូវជួយតែងតាំង អ្នកដែលមានគុណសម្បត្តិ ជានាយកប្រតិបត្តិ ហើយត្រូវណែនាំអំពីការចាត់តាំងបុគ្គលិកគ្រប់រូប ។ ពួកគេក៏នឹងណែនាំ អំពីវិធីផ្តល់ហិរញ្ញប្បទានដល់ការងាររបស់អង្គការផងដែរ ។

សមាជិកគណៈកម្មការផ្តល់ការប្រឹក្សាមួយរូបជាទីប្រឹក្សា/សាវនការហិរញ្ញវត្ថុដែលបានជ្រើសរើស ដើម្បីត្រួតពិនិត្យការងាររបស់ហិរញ្ញឹក/មន្ត្រីហិរញ្ញវត្ថុ ណែនាំអំពីបទដ្ឋានត្រឹមត្រូវសំរាប់ការងារហិរញ្ញវត្ថុ ដែលនឹងត្រូវរាយការណ៍ជូនទៅភ្នាក់ងារអ្នកផ្តល់ជំនួយ និង ដល់កិច្ចប្រជុំជាទូទៅ ។

## ប្រការ១២: គណៈកម្មការប្រតិបត្តិ

គណៈកម្មការប្រតិបត្តិ រួមមានអ្នកដែលជាប់ដោយសារការបោះឆ្នោតជាធម្មតា នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ ។ ក្នុងករណីមានការលាឈប់ពីតំណែង, មរណភាព ឬអសមត្ថភាពគណៈកម្មការប្រតិបត្តិនិងត្រូវជ្រើសជាថ្មី តាមរយៈការបោះឆ្នោតដោយយកសំលេងភាគច្រើន ក្នុងការដែលត្រូវធ្វើការងារការិយាល័យ បន្តរហូតដល់ដល់កិច្ចប្រជុំទូទៅប្រចាំឆ្នាំ ជាមួយនិងសមាជិកអង្គការ រួមជាមួយកិច្ចពិគ្រោះយោបល់និងគណៈកម្មការផ្តល់ការប្រឹក្សា ដែលតាមធម្មតាពួកគេនិងត្រូវបានរៀបចំការប្រជុំ បីដងក្នុងមួយឆ្នាំ ។

**ក)** នាយកអង្គការ និងត្រូវបានចាត់តាំងជាប្រធាននៃអង្គប្រជុំគណៈកម្មការប្រតិបត្តិ, ជាប្រធានកិច្ចប្រជុំទូទៅប្រចាំឆ្នាំ ហើយរៀបចំរបៀបវិរៈក្នុងកិច្ចពិភាក្សាជាមួយ នាយកប្រតិបត្តិ និងទីប្រឹក្សា។ គាត់នឹងត្រូវជាអ្នកធានានូវការអនុវត្តន៏នូវបទបញ្ជាផ្ទៃក្នុងរបស់បុគ្គលិក កោះហៅប្រជុំជាទូទៅប្រចាំឆ្នាំ និងរក្សានូវទំនាក់ទំនង រវាងនាយកប្រតិបត្តិ, ក្រុមផ្តល់ការប្រឹក្សា និងរដ្ឋបាលនៃគំរោង។

គាត់មានហត្ថលេខាមួយ នៃគណនីធនាគារអង្គការ គាត់អាចនិងត្រូវបានសុំឱ្យចុះហត្ថលេខាលើកិច្ចសន្យាជំនួសអង្គការ ។

**ខ)** អតីតនាយកអង្គការ អាចនិងត្រូវបានលើកទឹកចិត្តជាសមាជិកគណៈកម្មការប្រតិបត្តិក្នុងការពិគ្រោះយោបល់ និងជំនួយការឱ្យសមាជិកប្រតិបត្តិថ្មី ។

**គ)** លេខាកត់ត្រាត្រូវរក្សាទុកនូវកំណត់ហេតុនៃកិច្ចប្រជុំការងារប្រតិបត្តិ និងកិច្ចប្រជុំជាទូទៅ ហើយត្រូវរក្សាឯកសាររបស់អង្គការ និងជួយបង្កើតឡើងនូវបណ្តាញ website របស់អង្គការដូចជា www.angkorwatngo.com ។

**ឃ)** លេខាធិការនាំសារ ទទួលបន្ទុកក្នុងការធ្វើឱ្យមានភាពរីកចំរើន នូវបញ្ជីរឈ្មោះសមាជិកភាព និងជូនដំណឹងដល់សមាជិក គណៈកម្មការប្រតិបត្តិ អំពីកិច្ចប្រជុំនិមួយៗ ។ ជាមួយនិងប្រធានអង្គការ គេត្រូវឆ្លើយតបទៅនិងសំណួរ អំពីអង្គការ និងផ្តល់ជូននូវឯកសារដែលមានភាពសុក្រិត្យ ។

**ង)** ហិរញ្ញិក/មន្ត្រីហិរញ្ញវត្ថុ និងមានហត្ថលេខានៅក្នុងគណនី ធនាគារ។ ក្នុងកិច្ចពិភាក្សាជាមួយនាយកអង្គការ និងនាយកប្រតិបត្តិ ក្នុងការចាយវាយនិងការរៀបចំថវិកា របស់អង្គការ ។ ហិរញ្ញិក/មន្ត្រីហិរញ្ញវត្ថុ និងត្រូវធ្វើរបាយការណ៍ ហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនកិច្ចប្រជុំជាទូទៅ ។ របាយការណ៏ហិរញ្ញវត្ថុ និងត្រូវបានពិនិត្យដោយសាវនករ និងត្រួតពិនិត្យដោយ គណៈកម្មការ-ប្រតិបត្តិ និងផ្តល់ការប្រឹក្សា ។ ហិរញ្ញិក/មន្ត្រីហិរញ្ញវត្ថុ អាចសុំឱ្យចុះហត្ថលេខាលើកិច្ចសន្យាសំរាប់អង្គការ ។ គាត់នឹងត្រូវរៀបចំដាក់ហិរញ្ញប្បទាន, អំណោយ ចូលក្នុងគណនីធនាគារ ។

## ប្រការ១៣: ការងាររដ្ឋបាលនៃគំរោង

អ្នកគ្រប់គ្រងគំរោងទទួលបន្ទុកលើបុគ្គលិកដែលទទួលប្រាក់បៀវវត្សឧបត្ថម្ភ ទៅតាមតួនាទីនិងសមត្ថភាព របស់ពួកគេ ដែលពាក់ព័ន្ធ និងកិច្ចសន្យាក្នុងភាពជាដៃគូ ក្នុងគំរោងរបស់អង្គការ។ អ្នកគ្រប់គ្រងគំរោង, បុគ្គលិកអង្គការត្រូវបានជ្រើសរើសដោយគណៈកម្មការប្រតិបត្តិនិង និងផ្តល់ប្រឹក្សា ហើយត្រូវ បានទូទាត់ដោយប្រាក់បៀវវត្សសមស្របទៅតាមបទពិសោធន៍ និងកំរិតសមត្ថភាពរបស់ពួកគេ ដែលមិនត្រូវបានជំរាបជូនជាសារធារណៈ ។ អ្នកគ្រប់គ្រងគំរោង រៀបចំប្រតិបត្តិការងាររបស់អង្គការ ពីមួយថ្ងៃទៅមួយថ្ងៃ ដោយមានកិច្ចប្រជុំប្រចាំខែជាទៀងទាត់ជា

មួយបុគ្គលិក, ទូទាត់ជូនបុគ្គលិកជារៀងរាល់ខែ និងប្រមូលយកនូវបង្កាន់ដៃ សំរាប់ការដំណើរការរបស់ហិរញ្ញឹក/មន្ត្រីហិរញ្ញវត្ថុ ។ ហើយជាទូទៅអ្នកគ្រប់គ្រងគំរោងត្រូវទទួលខុសត្រូវ ចំពោះការអនុវត្តន៏សកម្មភាព ឱ្យមានភាពរលូន និងអភិវឌ្ឍន៏ក្នុងគំរោងរបស់អង្គការ និងវាយ តំលៃប្រសិទ្ធិភាពនៃកម្មវិធី ។ តាមគំរោង គាត់អាចធ្វើការចាត់តាំង បុគ្គលិកដែលមានប្រាក់បៀវត្សជាច្រើនរូប និងមានអ្នកជំនួយការ ដើម្បីសំរេចគោលបំណងនៃអង្គការ ។ គាត់នឹងត្រូវជួយរៀបចំរបាយការណ៏ប្រចាំឆ្នាំ អំពីការងារសំរាប់ការប្រជុំទូទៅប្រចាំឆ្នាំ ហើយអាចសូមឱ្យមានការចូលរួមពីស្ថាប័ននិងតំណាងអង្គការ នៅក្នុងសន្និបាតផ្សេងៗ និងកិច្ចប្រជុំជាមួយសហគមន៏ ក៏ដូចជាគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៏ខេត្ត និងអង្គការក្រៅរដ្ឋាភិបាលនានា ។ល។

អ្នកគ្រប់គ្រងគំរោងជួយដល់គណៈកម្មការប្រតិបត្តិ និង ផ្តល់ប្រឹក្សាក្នុងការរៀបចំធ្វើគំរោងផែនការសុំជំនួយ សំណើសុំថវិការ និងរបាយការណ៏ការងារបន្ត ។ គាត់ស្វែងរកទីប្រឹក្សា ឬជំនួយការផ្ទាល់ដោយផ្តល់ជូននូវប្រាក់កំរៃប្រចាំថ្ងៃ សំរាប់ការងារសិក្ខាសាលា ឬការងារអប់រំដោយផ្ទាល់នៅតាមមូលដ្ឋាន ។

## ប្រការ១៤: សារពើពន្ធ និងសាវនកម្ម ប្រចាំឆ្នាំ

ជាទូទៅសារពើរពន្ធ និងសាវនកម្មប្រចាំឆ្នាំ និងត្រូវធ្វើ ឱ្យស្របគ្នាជាមួយកិច្ចប្រជុំប្រចាំឆ្នាំដែលតែងតែប្រារព្ធធ្វើនៅរៀងរាល់ ខែមេសា ។

## ប្រការ១៥: ការធ្វើវិសោធនកម្មនៃលក្ខន្តិកៈ

ការធ្វើវិសោធនកម្មលក្ខន្តិកៈ តាមធម្មតាត្រូវកើតឡើងនៅក្នុង កិច្ចប្រជុំប្រចាំឆ្នាំ ហើយត្រូវការសំលេងភាគច្រើន ។ ជារឿយៗ និងត្រូវបានរៀបចំជាមុនដោយគណៈកម្មការប្រតិបត្តិ និងគណៈកម្មការផ្តល់ការប្រឹក្សា ។

## ប្រការ១៦: ការរំសាយ

ប្រសិនបើមានការចាំបាច់ ក្នុងការរំសាយអង្គការចោល កិច្ចប្រជុំពិសេសអាចត្រូវបានកោះហៅដើម្បីអនុមតិការរំសាយចោល ដោយផ្តល់នូវការយល់ព្រមពីសមាជិកសំលេង ពីរភាគបី ។

## ប្រការទី១៧: ការបែងចែកទ្រព្យសម្បត្តិ

នៅពេលរំសាយអង្គការចោល គណៈកម្មការប្រតិបត្តិ និងគណៈកម្មការផ្តល់ការប្រឹក្សា ដោយមានការពិគ្រោះយោបល់ពីនាយកគំរោង ត្រូវកំណត់ការបែងចែកទ្រព្យសម្បត្តិ ។ មូលនិធិដែលមិនទាន់ ចំណាយពី មូលនិធិ និងអ្នកផ្តល់ជំនួយផ្សេងៗ និងត្រូវបញ្ជូនទៅវិញដូចបានកំណត់ក្នុងលក្ខ័ណ្ឌនៃការផ្តល់អំណោយ បើពុំដូច្នោះទេ មូលនិធិ និងទ្រព្យសម្បត្តិ ដែលនៅសល់ និងត្រូវផ្តល់ជាអំណោយជូនដល់អង្គការដទៃ ឬស្ថាប័នរាជរដ្ឋាភិបាលដោយ មិនគិតពីផលប្រយោជន៍ផ្សេងៗ ដែលច្បាប់នៅប្រទេសកម្ពុជាបានកំណត់ ។

## ប្រការ១៨: អវសានប្បញ្ញត្តិ

សមាជិកគ្រប់ប្រភេទ និងបុគ្គលិកទាំងអស់ របស់អង្គការ ស.ស.ក.ស. ត្រូវតែគោរពតាមលក្ខន្តិកៈ, បទបញ្ជាផ្ទៃក្នុង ច្បាប់ធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់នានាជាធរមានឱ្យបានដាច់ខាត ។ លក្ខន្តិកៈអង្គការ ស.ស.ក.ស. នៅក្នុងខេត្តសៀមរាប មានសុពលភាព និងគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

សៀមរាប, ថ្ងៃទី ខែមិថុនា ឆ្នាំ២០០៣

**ប្រធាន**